វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា

ឆ្នាំ២០១៤ លេខ ០២

## ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំ សម្រាប់ឲ្យកម្ពុជាមានលក្ខណៈប្រកួតប្រជែង និងការច្នៃប្រឌិត

"ការវិនិយោគក្នុងវិស័យអប់រំ គឺជាការវិនិយោគទៅក្នុងជង្គើមសេដ្ឋកិច្ចរបស់យើង។"

*ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន*
*រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

### ការកសាងអនាគតប្រទេសកម្ពុជា

ការអភិវឌ្ឍធនធានមនុស្ស គឺជាគន្លឹះនៃជោគជ័យ នៅក្នុងដំណាក់កាលខាងមុខនៃការអភិវឌ្ឍនៅកម្ពុជា។ ដោយមានសេដ្ឋកិច្ចឡើងជិតដល់កម្រិតគេហៅថា មានប្រាក់ចំណូលមធ្យមកម្រិតទាបនោះ ប្រទេសកម្ពុជាត្រូវជៀសឲ្យផុតពី អន្ទាក់នៃប្រាក់ចំណូលមធ្យម ពោលគឺ ស្ថានភាពដែលកំណើន ផសស ក្នុងមនុស្សម្នាក់ វាលុបបំបាត់ ឧត្តមភាពប្រៀបធៀបបានពីកម្លាំងពលកម្មមានតម្លៃទាប ហើយធ្វើឲ្យកំណើន ផសស ត្រូវជាប់គាំង។ ការកសាងសមត្ថភាពធនធានមនុស្ស នឹងជួយឲ្យកម្លាំងពលកម្មជៀសផុតពីអន្ទាក់នេះ ដោយអាចចូលទៅបម្រើការនៅក្នុងផលិតកម្មទាមទារជំនាញកម្រិតខ្ពស់ៗ ធ្វើឲ្យកម្ពុជាមានលក្ខណៈប្រកួតប្រជែងនៅក្នុងទីផ្សារតែមួយនៃអាស៊ាន។

រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានបង្កើតគំរូគោលនយោបាយគ្រប់ជ្រុងជ្រោយជាច្រើន ដើម្បីត្រៀមរៀបចំកម្លាំងពលកម្មសម្រាប់ពេលអនាគត។ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ និង ទី២ និងផែនការយុទ្ធសាស្រ្តអប់រំឆ្នាំ២០០៩-២០១៣ (ESP) មានគោលដៅផ្តល់ការអប់រំមានស្តង់ដារត្រឹមត្រូវក្នុងទូទាំងប្រទេស, បង្កើនលទ្ធភាពឲ្យប្រជាជនគ្រប់គ្នាទទួលបានការអប់រំកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា, កសាងសមត្ថភាពរបស់គ្រូបង្រៀន/អ្នកបណ្តុះបណ្តាល, និងលើកកំពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ។ ធនធានបន្ថែមជាច្រើនត្រូវបាន និងកំពុងតែផ្តល់មកឲ្យទៀត សម្រាប់ការអនុវត្តគោលនយោបាយទាំងនេះ ធ្វើឲ្យចំណាយលើការអប់រំកើនឡើងប្រហែល ៦០% ពីឆ្នាំ២០០៧ ដល់ ២០១០។

ក្នុងពីរទសវត្សរ៍កន្លងមក រដ្ឋាភិបាលបានជឿនលឿនទៅមុខច្រើនក្នុងការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធអប់រំនៅកម្ពុជា ពិសេសក្នុងការកសាងសាលាបឋមសិក្សា ដោយសាងសង់បានជាមធ្យម ១០០សាលារៀនថ្មីក្នុងមួយឆ្នាំៗ ពីឆ្នាំ១៩៩៣ ដល់ ២០១៣ (រូបភាព ១)។

រូបភាព ១: ចំនួនសាលាបឋមសិក្សានៅកម្ពុជា




ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា

ការកសាងគោលនយោបាយ និងហេដ្ឋារចនាសម្ព័ន្ធផ្នែកអប់រំ បានញុំាងឲ្យការពង្រីកសេវាអប់រំទទួលបានលទ្ធផលច្រើនណាស់។ យោងតាមស្ថិតិរបស់រដ្ឋាភិបាល ប្រទេសកម្ពុជាជិតសម្រេចបាននូវ

អត្ថបទនេះ សង្ខេបចេញពី វគ្គទី២ នៃការពិភាក្សាតាមក្រុម ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៤។ អ្នកចូលរួមក្នុងវគ្គនេះ រួមមាន ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, លោក ម៉ក់ ចំរើន ប្រធានសមាគមយុវជនខ្មែរ, បណ្ឌិត ចិត្ត ជាលី សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, បណ្ឌិត Srinivasa Madhur ប្រធានផ្នែកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI និង លោក Martin McCarthy នាយកគ្រប់គ្រង និងតំណាងប្រចាំប្រទេស នៃក្រុមហ៊ុន Total Cambodia។ អ្នកសម្របសម្រួលវគ្គនេះ គឺ លោកស្រី Sandra D'Amico នាយកគ្រប់គ្រងក្រុមហ៊ុន HR Inc និង អនុប្រធានសហពន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា។

ការអប់រំបឋមសិក្សាជាសាកល ដោយមាន ៩៧% នៃកុមារក្នុងអាយុត្រូវចូលរៀននៅបឋមសិក្សា បានចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សា ២០១២-១៣។

ការបង្កើតប្រព័ន្ធអប់រំតាមស្តង់ដារពិភពលោក ដែលអាចជួយជំរុញឲ្យកម្ពុជាឆ្លងកាត់បាននូវ ដំណាក់កាលខាងមុខនៃការអភិវឌ្ឍ គឺជាកិច្ចការចម្បងមួយ ដោយត្រូវមានការកែលំអទាំងនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។មានផ្នែកសំខាន់ៗបីដែលត្រូវមានគោលនយោបាយដោះស្រាយ គឺ ១) ការបង្កើនគុណភាពការអប់រំនៅគ្រប់កម្រិត, ២) ការពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ក្នុងទូទាំងប្រទេស និង ៣) ការភ្ជិតគម្លាតរវាងជំនាញដែលត្រូវជំរុញសេដ្ឋកិច្ចឡើង នឹងជំនាញដែលប្រព័ន្ធអប់រំកំពុងផ្តល់ឲ្យ។

## វិធីសាស្ត្រផ្តោតលើគុណភាព

គុណភាពនៃការផ្តល់សេវាអប់រំ នៅតែមានបញ្ហាចោទ នៅក្នុងការអប់រំកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ ការយកចិត្តទុកដាក់លើស្ថិតិចុះឈ្មោះចូលរៀន ជារឿយៗបង្ហាញពី ភាពមិនគ្រប់គ្រាន់នៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។ បញ្ហាស្នូលមួយ គឺទាំងបឋមសិក្សា និងមធ្យមសិក្សា មានអត្រាបញ្ចប់ការសិក្សាកម្រិតទាបជាពិសេសនៅតាមតំបន់ជនបទ (រូបភាព ២)។

សព្វថ្ងៃនេះ គេត្រូវផ្លាស់ប្តូរ ចំណុចផ្តោតនៃការផ្តល់សេវាអប់រំ និងសូចនាករអនុវត្តគោលនយោបាយពាក់ព័ន្ធ ទៅអនុវត្តវិធីសាស្ត្រផ្តោតលើគុណភាព ជាពិសេសអត្រាបញ្ចប់ការសិក្សានៅគ្រប់កម្រិតអប់រំដោយយកវាធ្វើជា សូចនាកវាស់វែងលទ្ធផល។

ការបង្រៀន និងសម្ភារៈបង្រៀនមានគុណភាពទាប គឺជាលក្ខណៈមួយនៃប្រព័ន្ធអប់រំនៅកម្ពុជា នៅតាមគ្រឹះស្ថានអប់រំសាធារណៈកម្រិតបឋមសិក្សា និងមធ្យមសិក្សា ជាពិសេសនៅតាមជនបទ ដែលតែងខ្សត់ធនធានជាងគេ។ គ្រូបង្រៀននៅសាលាតាមជនបទ រកចំណូលបានប្រហែល ១០០ដុល្លារអាមេរិកក្នុងមួយខែ ហើយជារឿយៗត្រូវធ្វើការងារបន្ថែម។ បញ្ហានេះនាំឲ្យមានអំពើពុករលួយក្នុងការផ្តល់សេវាអប់រំ រួមទាំង ការលក់វិញ្ញាសាប្រឡងដល់សិស្សផង។

អំពើពុករលួយដែលកើតមាននៅក្នុងរចនាសម្ព័ន្ធបឋមសិក្សា និងមធ្យមសិក្សា មានន័យថា ការបង់ប្រាក់កម្រៃក្រៅផ្លូវការវាចាំបាច់ ដើម្បីទទួលបានជោគជ័យក្នុងការសិក្សា។ ចំណាយក្រៅផ្លូវការទាំងនេះបានបំបាក់ទឹកចិត្តគ្រួសារក្រីក្រ ក្នុងការបញ្ជូនកូនទៅរៀន និងនាំឲ្យអត្រាបោះបង់ការសិក្សាកើនឡើងក្នុងចំណោមសិស្សក្រីក្រ។

សិស្សនៅតំបន់ជនបទ មានលទ្ធភាពតិចជាងគេក្នុងការប្រើប្រាស់សម្ភារៈបរិក្ខារដ៏ចាំបាច់ៗ ដើម្បីសម្រេចជោគជ័យនៅក្នុងសេដ្ឋកិច្ចសម័យទំនើប។ សិស្សជាច្រើននៅតាមសាលាក្នុងតំបន់ជនបទ មានលទ្ធភាពតិច ក្នុងការបានប្រើប្រាស់សម្ភារៈផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT)។ កង្វះខាតនេះបានរាំងស្ទះលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានការអប់រំនៅឧត្តមសិក្សា ឬការងារមានបៀវត្សរ៍ខ្ពស់។

គន្លឹះដើម្បីកែលំអការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា នៅកម្ពុជា គឺការបង្កើនថវិកាសាធារណៈ និងការផ្តល់អាទិភាពដល់តំបន់ជនបទ។ ការងារនេះមានជាអាទិ៍ ការផ្តល់ថវិកាសម្រាប់សម្ភារៈបរិក្ខារ និងអាគារសិក្សា, ការតម្លើងបៀវត្សរ៍គ្រូបង្រៀន, ការផ្តល់ការបណ្តុះបណ្តាលកាន់តែប្រសើរដល់គ្រូបង្រៀនមុខវិជ្ជាស្នូល ដូចជា គណិតវិទ្យា ភាសាអង់គ្លេស និងវិទ្យាសាស្ត្រ, និងការធានាឲ្យ កុមារមានកម្រិតអាហារូបត្ថម្ភគ្រប់គ្រាន់ ដើម្បីអាចបំពេញបានតាមការទាមទាររបស់រាងកាយ និងបញ្ញា ក្នុងការរៀនសូត្រ។

ការអភិវឌ្ឍធនធានមនុស្សនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា ត្រូវមានការប្រឹងប្រែងហួសពីក្នុងថ្នាក់រៀនទៅទៀត។ សាលារៀនដែលទទួលបានជោគជ័យ តែងសម្រួលឲ្យក្រុមគ្រួសារបានចូលពាក់ព័ន្ធក្នុងការអប់រំរបស់សិស្ស និងលើកទឹកចិត្តពួកគេឲ្យបញ្ជូនកូនទៅសាលារៀន និងលើកកម្ពស់ការសិក្សានៅផ្ទះ ក្រៅពីម៉ោងរៀននៅសាលា។

រូបភាព ២: គម្លាតរវាងតំបន់ជនបទ នឹងទីក្រុងក្នុងការអប់រំកម្រិតមធ្យមសិក្សា




ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា

ការកសាងវប្បធម៌អប់រំនៅកម្ពុជា ត្រូវចាប់ផ្តើមពីបឋមវ័យ ដើម្បីឲ្យវាកំណត់នូវការចូលរួមរបស់សិស្សក្នុងការអប់រំ នៅពេលពួកគេទៅសាលារៀន។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋាភិបាលកំពុងលើកកម្ពស់ការអប់រំនៅមតេយ្យសាលា ដោយសង្ឃឹមថា នឹងអាចបង្កើនអត្រាចុះឈ្មោះចូលរៀនបានយ៉ាងច្រើនក្នុងរយៈពេលមធ្យម។

គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ក៏មានការបង្រៀន និងសម្ភារៈបរិក្ខារបង្រៀនគុណភាពទាបដែរ។ បញ្ហាធំមួយគឺ ការអប់រំកម្រិតឧត្តមសព្វថ្ងៃមានវិស័យឯកជនជាអ្នកជំរុញឡើង មានបទបញ្ញត្តិគ្រប់គ្រងអន់ខ្សោយ ហើយជារឿយៗ ផ្តល់អាទិភាពលើប្រាក់ចំណេញខ្ពស់ជាង លើគុណភាព។

ដោយគ្មានការត្រួតពិនិត្យគុណភាព ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពជំនាញមានស្តង់ដារច្បាស់លាស់ គ្រឹះស្ថានឧត្តមសិក្សា មាននិន្នាការផ្តល់ការបណ្តុះបណ្តាលមានគុណភាពអន់ និងសមត្ថភាពជំនាញគ្មានតម្លៃ។ បញ្ហានេះ អាចជាការខ្វះខាតធនធានរបស់ គ្រួសារដែលអាចទទួលបានព័ត៌មានមិនគ្រប់គ្រាន់ ដើម្បីវាយតម្លៃពីលក្ខណៈសមហេតុផលនៃការបង់ថ្លៃដើម្បីរៀនយកជំនាញបែបនេះ។

សមត្ថភាពទាប និងបទបញ្ញត្តិអន់ខ្សោយផ្នែកគ្រឹះស្ថានឧត្តមសិក្សា បានប៉ះពាល់អវិជ្ជមាន ដល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដោយសារគេបានជ្រើសរើសបុគ្គលិកមានការបណ្តុះបណ្តាលមិនល្អ នៅឧត្តមសិក្សា ឲ្យមកបង្រៀនវគ្គ TVET ធ្វើឲ្យបញ្ហាគុណភាពរាលដាលដល់ទីនោះទៀត។

ការណែនាំពីអាជីពសមស្របដល់និស្សិត និងបទបញ្ញត្តិតឹងរឹងលើគ្រឹះស្ថានឧត្តមសិក្សា មានទាំងការត្រួតពិនិត្យ ការវាយតម្លៃ និងការកំណត់ស្តង់ដារនៃវគ្គសិក្សា និងគុណភាពផង នឹងជួយដោះស្រាយបញ្ហាគុណភាពអប់រំ នៅតាមគ្រឹះស្ថានឧត្តមសិក្សា និង TVET។

បើសិនប្រព័ន្ធអប់រំនៅកម្ពុជា ចង់ផ្តល់នូវពលករមានជំនាញខ្ពស់ក្នុងផ្នែកបច្ចេកវិទ្យាខ្ពស់ៗនោះ គេត្រូវកែលំអសម្ភារៈបរិក្ខារនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ឧបសគ្គចម្បងមួយ គឺកង្វះមន្ទីរពិសោធន៍សម្រាប់បង្រៀនជំនាញវិទ្យាសាស្ត្រ ក្នុងមុខវិជ្ជាស្នូល ដូចជា ជីវវិទ្យា គីមីវិទ្យា និងរូបវិទ្យា។ ការអភិវឌ្ឍជំនាញទាំងនេះ ចាំបាច់ណាស់សម្រាប់ឧស្សាហកម្មប្រើបច្ចេកវិទ្យាខ្ពស់ ដូចជា វិស្វកម្មគីមី ឧស្សាហកម្មផ្នែកវេជ្ជសាស្ត្រនិងឱសថ និងវិស្វកម្មផ្នែកមេកានិក។

ការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់មូលនិធិដល់ គ្រឹះស្ថានបណ្តុះបណ្តាលជំនាញផ្នែកវិទ្យាសាស្ត្រខ្ពស់ៗ និងតាមស្តង់ដារពិភពលោក ក៏សំខាន់ដែរ ព្រោះវាហុចអត្ថប្រយោជន៍ដល់ក្រុមហ៊ុនដែលត្រូវការពលករមានជំនាញខ្ពស់។ ការកសាងគ្រឿងសម្រួលការបែបនេះ នឹងទាក់ទាញអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ឲ្យចូលមកគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា។ វិធីនេះសំខាន់បំផុត សម្រាប់ការបង្កើតវប្បធម៌ស្រាវជ្រាវដ៏ប្រសើរ ដែលនឹងជួយដល់ការបង្រៀនមានគុណភាពខ្ពស់។

## ការពង្រីកលទ្ធភាពទទួលបានការអប់រំ

កន្លងមកលទ្ធភាពទទួលបានការអប់រំកម្រិតបឋមសិក្សាបានកើនឡើងជាខ្លាំង ប៉ុន្តែលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា នៅតែមានបញ្ហាដែលរដ្ឋាភិបាលត្រូវដោះស្រាយ។ នៅកម្រិតអនុវិទ្យាល័យ ការចុះឈ្មោះចូលរៀនបានធ្លាក់ចុះពី ៥៥% នៅឆ្នាំ២០១១-២០១២ ដល់ ៥៣% នៅឆ្នាំ២០១២-១៣ និងនៅកម្រិតវិទ្យាល័យ បានធ្លាក់ចុះពី ៣០,៦% ដល់ ២៧%។ ជាទូទៅអត្រាចុះឈ្មោះចូលរៀននៅតំបន់ជនបទ វាតែងទាបជាង នៅតំបន់ទីក្រុង (រូបភាព ២)។

រដ្ឋាភិបាលបានប្តេជ្ញាចិត្តដើម្បី បង្កើនអត្រាចុះឈ្មោះចូលរៀនដោយបានកសាងសាលារៀនបន្ថែម ជាពិសេសនៅតាមតំបន់ជនបទ និងដាច់ស្រយាល, បង្កើនការលើកទឹកចិត្តដល់គ្រូឲ្យទៅធ្វើការនៅតំបន់ជាយៗ, លើកទឹកចិត្តសិស្សឲ្យចូលរៀននៅមធ្យមសិក្សា, និងបណ្តុះវប្បធម៌អប់រំក្នុងសង្គមកម្ពុជា ដោយបញ្ចូលមាតាបិតាសិស្សទៅក្នុងការសិក្សា។

បញ្ហាសិស្សបោះបង់ការសិក្សាមុនពេលបញ្ចប់ថ្នាក់វិទ្យាល័យ ធ្វើឲ្យប្រជាជនជាច្រើនមានជំនាញទាប ដោយភាគច្រើនអាចចូលរួមបានតែក្នុងការងារកសិកម្ម និងឧស្សាហកម្មគ្មានជំនាញ។ បញ្ហាចម្បងសម្រាប់រដ្ឋាភិបាលគឺ ធ្វើយ៉ាងណាអាចផ្ទេរជំនាញទៅឲ្យប្រជាជន ៦៣% នេះ ដើម្បីឲ្យពួកគេអាចរកបានការងារធ្វើ មានកម្រិតជីវភាពប្រសើរឡើង និងអាចជួយជំរុញសេដ្ឋកិច្ចទៅមុខទៀត។ អ្នកបង្កើតគោលនយោបាយបានសន្និដ្ឋានថា ការពង្រីក TVET អាចជាដំណោះស្រាយលើបញ្ហានេះ។

ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ ការពង្រីក TVET មានការជឿនលឿនច្រើនណាស់ ដោយកើនពី វិទ្យាស្ថានមួយចំនួនតូចនៅដើមទសវត្សរ៍១៩៩០ ដល់ជាង ៣០០ វិទ្យាស្ថាននៅឆ្នាំ២០១២។ ប៉ុន្តែកំណើននេះនៅទាបជាខ្លាំងបើធៀបទៅនឹងតម្រូវការ និងបើធៀបនឹងចំនួនពលករគ្មានជំនាញដែលប្រព័ន្ធសិក្សាអប់រំនៅកម្ពុជាផលិតបានជារៀងរាល់ឆ្នាំ។

ដើម្បីបង្កើនចំនួនវិទ្យាស្ថាន TVET ត្រូវមានកំណើនការផ្តល់មូលនិធិសាធារណៈ និងការចូលរួមជាបន្តពីវិស័យឯកជន។ នៅឆ្នាំ២០១២ ក្នុងចំណោមវិទ្យាស្ថានទាំងអស់ ៣៣១ មាន ៥៥ ទទួលមូលនិធិពីវិស័យសាធារណៈ, ២២៧ ទទួលមូលនិធិពីវិស័យឯកជន, និង ៤៩ ទទួលមូលនិធិពីអង្គការមិនមែនរដ្ឋាភិបាល។ ការចូលរួមរបស់វិស័យឯកជនក្នុង TVET ត្រូវតែពង្រឹងបន្ថែម ហើយត្រូវបង្កើតយន្តការសម្រាប់បង្កើតភាពជាដៃគូថ្មីៗទៀតជាមួយវិស័យឯកជន។

បច្ចុប្បន្នមានគម្លាតយ៉ាងធំរវាងទីក្រុង នឹងជនបទ ក្នុងការទទួលបានសេវាអប់រំបណ្តុះបណ្តាល TVET។ មានវិទ្យាស្ថានតិចតួចណាស់ដែលស្ថិតនៅក្រៅទីក្រុង ហើយគ្រួសារជាច្រើននៅតាមជនបទ មិនមានពេលវេលា និងធនធានសម្រាប់ចំណាយដើម្បីទទួលបានសេវាអប់រំនិងបណ្តុះបណ្តាល និង/ឬ មិនបានដឹងពីអត្ថប្រយោជន៍នៃ TVET ទេ។ បញ្ហានេះបានចូលរួមបង្កើនភាពគ្មានការងារធ្វើនៅតាមជនបទ ហើយទីផ្សារការងារនៅកម្ពុជាក៏គ្មានប្រសិទ្ធភាព ពីព្រោះពលករដែលនៅសល់ពីកសិកម្ម មិនអាចទទួលបានជំនាញដ៏ចាំបាច់ដើម្បីចូលរួមចំណែកក្នុងវិស័យផ្សេងទៀតនៃសេដ្ឋកិច្ចទេ។

ការពង្រីកកម្មវិធីបណ្តុះបណ្តាល ឲ្យបានទៅដល់តំបន់ជាយៗ មានជួបបញ្ហាជាច្រើន ដែលអ្នកបង្កើតគោលនយោបាយត្រូវជំនះឲ្យបាន។ តួអង្គក្នុងវិស័យឯកជនអាចមិនសូវចង់ផ្តល់មូលនិធិដល់វិទ្យាស្ថាន TVET ដែលនៅឆ្ងាយពីមជ្ឈមណ្ឌលផលិតកម្មនោះទេ, មូលនិធិសាធារណៈសម្រាប់គម្រោងបែបនេះគឺមានកម្រិត, ហើយបៀវត្សរ៍ទាប ក៏ធ្វើឲ្យអ្នកបណ្តុះបណ្តាលមិនសូវចង់ទៅធ្វើការនៅតំបន់ជាយៗដែរ។

ទោះជាការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា បានកើនឡើងពី ១២,៩% នៅឆ្នាំ២០១០ ដល់ ១៤,៥% នៅឆ្នាំ២០១១ ក្តី ក៏និស្សិត

ភាគច្រើនសុទ្ធតែមានក្រុមគ្រួសារជាអ្នកធូរធារ និង/ឬ រស់នៅតំបន់ទីក្រុង។ មានអាហារូបករណ៍តិចតួចណាស់ដែលសម្រាប់ផ្តល់ឲ្យនិស្សិតមកពីគ្រួសារក្រីក្រ ដើម្បីចូលរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សា ហើយនៅតំបន់ជនបទក៏ខ្វះខាតការយល់ដឹងអំពី ឱកាសសម្រាប់ការសិក្សាអប់រំនៅឧត្តមសិក្សាដែរ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) របស់រដ្ឋាភិបាល បានគូសបញ្ជាក់ពី តម្រូវការនូវកម្មវិធីផ្សព្វផ្សាយ និងអាហារូបករណ៍ ដើម្បីបង្កើនចំនួនសិស្សពូកែសម្រាប់ការអប់រំនៅឧត្តមសិក្សា និងការលើកកម្ពស់សមធម៌ក្នុងលទ្ធភាពទទួលបានសេវាអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា។

## ការដោះស្រាយបញ្ហាជំនាញមិនស៊ីគ្នានឹងតម្រូវការ

រចនាសម្ព័ន្ធទីផ្សារការងារនៅកម្ពុជា វាមិនឆ្លុះបញ្ចាំងពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ឬទៅអនាគតនោះទេ។ បញ្ហាចម្បងមួយគឺ ចំនួនច្រើនលើសតម្រូវការនៃពលករដែលបញ្ចប់ការសិក្សាតែមានជំនាញមិនសមស្រប និងកង្វះខាតពលករពាក់កណ្តាលជំនាញ។ វិទ្យាស្ថាន CDRI បានព្យាករថា នៅឆ្នាំ២០១២ ទីផ្សារការងារនឹងត្រូវការនិស្សិតបញ្ចប់ការសិក្សាប្រមាណ ១៦.០០០នាក់ ប៉ុន្តែគ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលបានដល់ទៅ ២៩.០០០នាក់ ហើយគេប៉ាន់ស្មានថា តួលេខនេះនឹងឡើងដល់ ២២.០០០នាក់ ទល់នឹង ៧០.០០០នាក់ នៅឆ្នាំ២០១៤ ។

និន្នាការនេះបង្ហាញថា ធនធានអប់រំនៅកម្ពុជាមិនទាន់បានយកមកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពទេ ហើយជាលទ្ធផល គឺការផុសឡើងនូវ ពលករមានជំនាញខ្ពស់លើសពីតម្រូវការ ដែលមានការទាមទារយ៉ាងខ្ពស់មិនអាចបំពេញឲ្យបាន។

អ្នកបង្កើតគោលនយោបាយត្រូវជានាថា ប្រព័ន្ធអប់រំនៅកម្ពុជាជួយភ្ជិតគម្លាតរវាង ជំនាញ/ចំណេះដឹង ដែលបានផ្តល់ទៅឲ្យនិស្សិតនឹងតម្រូវការជាក់ស្តែងនៅឯកន្លែងធ្វើការ។ ដូច្នេះគេត្រូវដោះស្រាយឧបសគ្គខាងផ្នែកផ្គត់ផ្គង់ ដើម្បីអភិវឌ្ឍជំនាញក្នុងវិស័យសេវាកម្មសំដៅជំរុញសកម្មភាពទទួលស្វាគមន៍ និងទេសចរណ៍នៅកម្ពុជា ព្រមទាំង ជំនាញបច្ចេកទេសសម្រាប់ជំរុញសកម្មភាពកាត់ដេរ និងកម្មន្តសាល។

ការកសាងកម្លាំងពលកម្មឲ្យមានសមត្ថភាពខ្ពស់ ដើម្បីពង្រឹងសសរស្តម្ភនៃកំណើនទាំងនេះ នឹងធានាឲ្យកម្ពុជាមានសមត្ថភាពប្រកួតប្រជែងនៅក្នុងទីផ្សារតែមួយនៃអាស៊ាន និងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាកាន់តែទាក់ទាញបានខ្លាំងនូវ វិនិយោគផ្ទាល់ពីបរទេស។

បញ្ហាសំខាន់មួយ គឺការលើកទឹកចិត្តនិស្សិតឲ្យចូលរៀនក្នុង TEVT ជាជាងរៀនយកសញ្ញាប័ត្រដើម្បីក្លាយជាបុគ្គលិកតាមការិយាល័យ។ សព្វថ្ងៃក្នុងគំនិតមហាជន TEVT មានរូបភាពអវិជ្ជមានមួយថាជាប់ទាក់ទងនឹងការងារប្រើកម្លាំងកាយ។ រូបភាពបែបនេះនៃ TVET ត្រូវតែផ្លាស់ប្តូរឲ្យបាន ដើម្បីឲ្យនិស្សិតដកចិត្តចេញពីកម្មវិធីសិក្សាសម្រាប់ទៅបម្រើការងារនៅតាមការិយាល័យ។

សិស្ស និងក្រុមគ្រួសាររបស់គេ ក៏ត្រូវទទួលបានការណែនាំអំពីអាជីពដ៏សមស្របផ្សេងៗដែរ ដើម្បីឲ្យពួកគេមានបំណងប្រាថ្នា និងការរំពឹងសង្ឃឹម ប្រាកដនិយម។ គ្រួសារជាច្រើនប្រហែលរំពឹងថាកូនចៅខ្លួននឹងទទួលបានការងារក្នុងការិយាល័យនៅពេលបញ្ចប់ការសិក្សា ប៉ុន្តែជារឿយៗវាមិនបានដូច្នោះទេ។

កម្មវិធីសិក្សានៅគ្រប់កម្រិត ត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់និយោជកប្រសិនបើគេចង់ឲ្យពលករមានជំនាញសមស្រប។ការត្អូញត្អែរដូចគ្នាមួយរបស់និយោជកក្នុងវិស័យកម្មន្តសាល និងសេវាកម្មគឺកង្វះការសង្កត់ធ្ងន់លើការអភិវឌ្ឍជំនាញទន់ ដែលបានរារាំងដល់ការរីកចម្រើនក្នុង ឥរិយាបថនៅកន្លែងធ្វើការ ការដោះស្រាយបញ្ហា និងគំនិតច្នៃប្រឌិត។

ការបង្កើតយន្តការប្រកបដោយប្រសិទ្ធភាព ដែលធានាឲ្យតម្រូវការនៃវិស័យឯកជនមានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីសិក្សា គឺសំខាន់ណាស់ សម្រាប់ឲ្យកម្ពុជាធ្វើពិពិធកម្មចូលទៅក្នុងឧស្សាហកម្មថ្មីៗ និងឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃ។

បញ្ហាមួយដែលអាចរារាំងដល់ការអភិវឌ្ឍឧស្សាហកម្ម គឺកង្វះការផ្តោតទៅលើមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលធ្វើឲ្យកម្ពុជាជួបកង្វះអ្នកវិទ្យាសាស្ត្រ វិស្វករ និងអ្នកជំនាញវិជ្ជាជីវៈខ្ពស់ៗផ្សេងទៀត។ ធនធានមនុស្សបែបនេះ ចាំបាច់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា និងការធ្វើពិពិធកម្មសេដ្ឋកិច្ចតាមរយៈ ការចាប់យកបាននូវដំណើរការឧស្សាហកម្មថ្មីៗ។

វិស័យឯកជន ជាពិសេស ក្រុមហ៊ុនពហុជាតិដែលមានទីតាំងនៅកម្ពុជា បានវាយតម្លៃបញ្ហាជំនាញមិនស៊ីគ្នានឹងតម្រូវការនេះ ថាជា ឧបសគ្គធំបំផុតដល់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។ នាបច្ចុប្បន្ន កម្មវិធីសិក្សាទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា មិនមានការបណ្តុះបណ្តាលគ្រប់គ្រាន់ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រនោះទេ។ បញ្ហានេះបានធ្វើឲ្យនិស្សិតដែលចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សាក្នុងមុខវិជ្ជាបច្ចេកទេសដែលទាមទារនូវចំណេះដឹងច្បាស់លាស់ក្នុងមុខវិជ្ជាស្នូលតាំងពីមធ្យមសិក្សាមក ត្រូវចាញ់និស្សិតនៅក្នុងប្រទេសឯទៀតៗ។

ក្រុមហ៊ុនពហុជាតិដែលចូលរួមក្នុង ការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ជារឿយៗត្រូវចំណាយធនធានបណ្តុះបណ្តាលនិស្សិតលើមុខវិជ្ជា ដែលគួរតែបានចេះចាំតាំងពីនៅមធ្យមសិក្សា។ ដូច្នេះជាការចាំបាច់ណាស់ដែលត្រូវដាក់បញ្ចូលមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ទៅក្នុងកម្មវិធីសិក្សារបស់សិស្សតាំងពីវ័យក្មេងខ្ចី ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់បង្កើនជំនាញកម្លាំងពលកម្ម នៅពេលពួកគេចូលរៀននៅឧត្តមសិក្សា។

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារអេអិនហ្សិតរ៉ូយ៉ាល់ ទេ។*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤

e-mail: cdri@cdri.org.kh, website: www.cdri.org.kh